# របៀបប្រើផ្ទាំងរូបភាពគ្រឹះមាំសង្ខេបក្នុងការផ្សាយដំណឹងល្អ

យើងបានបង្កើតផ្ទាំងរូបភាពនេះ :

១. ដើម្បីជួយគ្រីស្ទានក្នុងការផ្សាយដំណឹងល្អអំពីសេចក្ដីសង្គ្រោះ ដោយមិនភ្លេចចំណុចសំខាន់ៗជាងគេ។

២. ដើម្បីជួយដល់គ្រីស្ទានដែលមិនចេះអានអក្សរ ព្រោះរូបភាពអាចជួយពួកគេអោយនឹកចាំពីរបៀបក្នុងការផ្សាយដំណឹងល្អ។

៣. ដើម្បីជួយពួកអ្នកដឹកនាំក្រុមជំនុំ ក្នុងការបង្ហាត់បង្រៀនសមាជិករបស់ខ្លួនអោយចេះផ្សាយដំណឹងល្អ។

៤. ដើម្បីជួយគ្រីស្ទានអោយទទួលខសំខាន់ ៧ ដែលនឹងជួយពួកគេ ក្នុងការផ្សាយដំណឹងល្អ។

មាន ៧ រូបភាព។ រូបភាពនិមួយៗមានចំណុចសំខាន់បី:

## រូបភាពទី ១: ព្រះ ទេវតា និង កំណើតលោកិយ

ក. ព្រះ គោលបំណងសំខាន់ក្នុងការផ្សាយដំណឹងល្អ គឺធ្វើអោយព្រះនាមព្រះជាម្ចាស់បានល្បី។ ចូរចាប់ផ្ដើមផ្សាយដំណឹងល្អដោយប្រាប់គេអំពីលក្ខណៈអស្ចារ្យនៃព្រះជាម្ចាស់។ (នៅខាងក្រោមផ្ទាំងនេះ មានការរំលឹកអំពីលក្ខណៈអស្ចារ្យខ្លះរបស់ព្រះជាម្ចាស់)។ ព្រះជាម្ចាស់បានបង្កើតពិភពលោក ហើយទ្រង់ជាអ្នកគ្រប់គ្រងរបស់វា។ ព្រះជាម្ចាស់ជាអ្នកគ្រប់គ្រង ល្អ បរិសុទ្ធ សប្បុរស និងយុត្តិធម៌ (រូបមកុដរំលឹកយើងអំពីភាពជាមហាក្សត្ររបស់ទ្រង់)។

ខ. ពួកទេវតា. មុនពេលព្រះជាម្ចាស់បានបង្កើតពិភពលោក ទ្រង់បានបង្កើតវិញ្ញាណច្រើនរាប់មិនអស់ដើម្បីបំរើព្រះអង្គ។ យើងហៅវិញ្ញាណទាំងនោះថា ពួកទេវតា។ ព្រះបានបង្កើតពួកទេវតាមកសុទ្ធតែល្អ ពីព្រោះព្រះជាម្ចាស់ល្អបរិសុទ្ធ។ ព្រះបានបង្កើតពួកទេវតាអោយមានអំណាចចេស្ដាជាងមនុស្សយើង ប៉ុន្តែមិនមានអំណាចចេស្ដាដូចព្រះជាម្ចាស់ទេ។ សូម្បីតែទេវតាដែលមានអំណាចចេស្ដាជាងគេបំផុត គឺប្រៀបដូចជាស្រម៉ោចដ៏តូច បើប្រៀបធៀបនឹងព្រះជាម្ចាស់។

គ. កំណើតលោកិយ. គ្រាន់តែមានបន្ទូល នោះព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើទាំងអស់។ ទ្រង់បានបង្កើតរុក្ខជាតិគ្រប់មុខ និង សត្វគ្រប់ប្រភេទទាំងអស់នៅលើផែនដី។ ចុងក្រោយបង្អស់ទ្រង់បានបង្កើតរបស់ដែលសំខាន់ជាងអ្វីៗទាំងអស់: គឺជាមនុស្សប្រុស និងមនុស្សស្រីដំបូងគេ ដើម្បីអោយពួកគេគ្រប់គ្រង ហើយទទួលខុសត្រូវលើផែនដី។ ព្រះអង្គបានបង្កើតអ័ដាម និងអេវ៉ា អោយដូចនឹងរូបអង្គទ្រង់ (ដូចជាស្រោមដៃគេបានធ្វើវាមក អោយត្រូវនឹងដៃរបស់មនុស្ស)។ មានន័យថាទ្រង់បានបង្កើតយើងមក អោយយើងអាចស្គាល់ទ្រង់ និយាយជាមួយទ្រង់ ស្ដាប់បង្គាប់ទ្រង់ គាប់ចិត្តនឹងព្រះអង្គ ហើយរស់នៅជាមួយព្រះអង្គជារៀងរហូត។ ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រីមកយ៉ាងល្អឥតខ្ចោះ ដោយគ្មានបាបសោះ។ ពីព្រោះ គ្មានអំពើបាប គ្មានសេចក្ដីស្លាប់ គ្មានជំងឺ គ្មានការលែងលះគ្នា គ្មានជំលោះ គ្មានសង្គ្រាម និងគ្មានទុក្ខព្រួយសោះ។ មនុស្សស្រី និងមនុស្សប្រុសដំបូង មានមិត្តភាពយ៉ាងល្អឥតខ្ចោះនឹងព្រះជាម្ចាស់ ពួកគេរស់នៅក្នុងពន្លឺនៃព្រះពរពីព្រះជាម្ចាស់។ ប៉ុន្តែព្រះជាម្ចាស់បានព្រមានគេថា បើសិនពួកគេបដិសេធមិនស្ដាប់តាមទ្រង់ទេ ពួកគេនឹងត្រូវស្លាប់ ហើយបែកចេញពីព្រះជាម្ចាស់ជារៀងរហូត។ (ចូរសូត្រ វិវរណៈ ៤:១១) ប៉ុន្តែភាពល្អឥតខ្ចោះ ភាពនៃការសប្បាយរីករាយនេះ នៅមិនបានយូរប៉ុន្មានទេ . . .

## រូបភាពទី ២ : ការបះបោរ

ក. ការបះបោររបស់សាតាំង. ព្រះគម្ពីរបាននិយាយថា ទេវតាដែលមានអំណាចខ្លាំងជាងគេ រួមជាមួយនឹងទេវតាមួយចំនួនទៀត បានបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ ព្រះជាម្ចាស់បានជ្រាបពីការនេះទាំងអស់មុនដែលវានឹងកើតឡើង ហើយទ្រង់អាចនឹងបញ្ឈប់មិនអោយវាកើតឡើងបាន ប៉ុន្តែទ្រង់មានផែនការណ៍សំរាប់ការនេះ។ គម្ពីរហៅទេវតាដែលមានបាបនេះថា "សាតាំង" ដែលមានន័យថា "សត្រូវ" ហើយពួកទេវតាផ្សេងទៀតដែលតាមវា យើងហៅថា "ពួកអារក្ស ព្រាយ បីសាច"។ ពួកវាជាមេកុហកបោកប្រាស និងជាឃាដករ ហើយពួកវាស្អប់ព្រះ និងស្អប់ការល្អខ្លាំងណាស់។ ព្រះជាម្ចាស់បានបណ្ដេញសាតាំង និងពួកអារក្សដែលជាបរិវាររបស់វា ចេញពីស្ថានសួគ៌ ហើយទ្រង់បានទំលាក់ពួកវាមកផែនដី។

ខ. អ័ដាម និង អេវ៉ា បានចូលរួមក្នុងការបះបោររបស់សាតាំង. សាតាំងបានល្បួងនាំ អ័ដាម និង អេវ៉ា អោយបែរចេញពីព្រះជាម្ចាស់។ វាបានប្រាប់ពួកគេថា ពួកគេអាចក្លាយទៅជាព្រះដោយខ្លួនឯងផ្ទាល់ ដោយមិនបាច់ពឹងលើព្រះជាម្ចាស់តទៅទៀត (សូមសំគាល់មើល មកុដនៅក្បាលរបស់គេ)។ កូនចៅរបស់អ័ដាមទាំងអស់កើតមកបានដាច់ចេញពីព្រះជាម្ចាស់ ដូចជាអ័ដាមដែរ។ យើងចង់បានទឹក ម្ហូបអាហារ ខ្យល់ ព្រះអាទិត្យ ហើយនឹងជីវិត ដែលព្រះបានបង្កើតមក ប៉ុន្តែយើងអត់ចង់បានព្រះជាម្ចាស់សោះ។ រៀងរាល់ថ្ងៃយើងបានប្រើប្រាស់អំណោយជាច្រើនរបស់ព្រះជាម្ចាស់ ប៉ុន្តែយើងបដិសេធមិនព្រមអរគុណទ្រង់សោះ។ យើងថែមទាំងយកអំណោយរបស់ព្រះជាម្ចាស់ ទៅសែនអោយអារក្សសាតាំងវិញ។ យើងមានចិត្តអាត្មានិយម ហើយមានគំនិត និងការប្រព្រឹត្តអាក្រក់ចំពោះអ្នកដទៃ។ ទាំងអស់នេះហើយដែលគម្ពីរហៅថា "បាប"។

គ. ព្រះជាម្ចាស់មិនព្រមអោយការបះបោរនៅតែបន្តរហូតទេ។ ព្រះជាម្ចាស់ល្អបរិសុទ្ធ។ ពួកអារក្ស និងមនុស្សដែលពេញដោយអំពើបាប មិនអាចរស់នៅជាមួយនឹងព្រះជាម្ចាស់បានឡើយ។ នៅពេលដែលអ័ដាម និងអេវ៉ាបានកាន់ជើងអារក្សប្រឆាំងនឹងព្រះ ពួកគេបានដាច់ចេញពីព្រះជាម្ចាស់ភ្លាម ដូចអ្វីដែលព្រះបានប្រាប់ពួកគេជាមុន ថានឹងត្រូវកើតឡើង។ ចិត្តគំនិតរបស់ពួកគេបានផ្លាស់ប្រែភ្លាមដែលពេញទៅដោយអំពើបាប។ បាប និងសេចក្ដីស្លាប់បានចូលមកក្នុងពិភពលោក ដែលនាំអោយមាន សង្គ្រាម សេចក្ដីសំអប់ ការលែងលះគ្នា ជំងឺ និងការឈឺចាប់។ ជំនួសអោយការដែលរស់នៅក្នុងពន្លឺនៃព្រះគុណរបស់ព្រះជាម្ចាស់ ឥឡូវមនុស្សរស់នៅក្នុងភាពងងឹតក្រោមអំណាចត្រួតត្រាដ៏អាក្រក់របស់សាតាំង។ (ចូរបង្ហាញ ជញ្ជាំងខ្ពស់ក្រាស់រវាងយើង ហើយនឹងព្រះជាម្ចាស់) (ចូរសូត្រ រ៉ូម ៣:១០-១២)។

## រូបភាពទី ៣ : លទ្ធផលដ៏អាក្រក់នៃបាបរបស់យើង

ក. ការដាច់ចេញពីព្រះជាម្ចាស់។ ជញ្ជាំងរវាងយើង នឹងព្រះជាម្ចាស់ គឺជាអំពើបាប និងការបះបោររបស់យើង ដែលបានផ្ដាច់យើងចេញពីព្រះជាម្ចាស់ ហើយជាហេតុដែលនាំអោយយើងរស់នៅក្នុងភាពងងឹត។ មនុស្សដែលចូលរួមក្នុងការបះបោររបស់សាតាំង មិនអាចមានមេត្រីភាពជាមួយនឹងព្រះជាម្ចាស់បានឡើយ។ ព្រះបានដាក់ទោសចំពោះពួកអ្នកបះបោរ ទៅតាមអ្វីដែលពួកគេចង់បាន គឺរស់នៅដោយគ្មានព្រះជាម្ចាស់។ ព្រះជាម្ចាស់កាត់យើងចេញពីវត្តមានរបស់ទ្រង់។ យើងមិនអាចធ្វើអ្វីដោយខ្លួនឯង ដើម្បីអោយព្រះជាម្ចាស់ទទួលយើងឡើងវិញបានឡើយ។

ខ. សេចក្ដីស្លាប់ និងការពុករលួយនៃរូបកាយ។ ដោយសារព្រះជាម្ចាស់ជាប្រភពជីវិតតែមួយគត់ ការដាច់ចេញពីព្រះអង្គ មានន័យថារូបកាយរបស់យើងត្រូវស្លាប់ ដូចជាមែកឈើដែលដាច់ចេញពីដើម វាត្រូវតែងាប់។

គ. ការដាច់ចេញពីព្រះអស់កល្បជានិច្ចនៅក្នុងស្ថាននរក.  ការដាក់ទោសចុងក្រោយ គឺព្រះជាម្ចាស់នឹងកាត់យើងចេញពីវត្តមានរបស់ទ្រង់ជារៀងរហូត ដាក់នៅក្នុងកន្លែងធ្វើទោស ដែលហៅថា ស្ថាននរក។  នេះគឺជាការដាស់ទោសដ៏យុត្តិធម៌ ព្រោះពួកអ្នកបះបោរគេមិនចង់បានព្រះ  បដិសេធមិនស្រឡាញ់ព្រះ  និងមិនព្រមដឹងគុណចំពោះព្រះជាម្ចាស់សោះ។ (ចូរសូត្រ ហេព្រើរ ៩:២៧) ប៉ុន្តែ តើចប់តែប៉ុណ្ណឹងឬ? តើគ្មានសេចក្តីសង្ឃឹមចំពោះអ្នកបះបោរដូចជាយើងឬ?

រូបភាពទី ៤ :  ដំណឹងល្អ :  ដោយព្រោះសេចក្តីស្រឡាញ់របស់ទ្រង់  ព្រះជាម្ចាស់បានចាត់អ្នកសង្គ្រោះមក ដើម្បីផ្សះផ្សាយើងដែលជាអ្នកបះបោរជាមួយនឹងទ្រង់ឡើងវិញ
ក. ព្រះជាម្ចាស់មិនបានបោះបង់ចោលយើងទៅតាមអំពើបាប និងការបះបោររបស់យើងទេ។  ចាប់តាំងពីដំបូងនៃការបះបោររបស់យើង  ព្រះជាម្ចាស់បានសន្យាថា នឹងចាត់អ្នកសង្គ្រោះមក ដែលនឹងបំផ្លាញអារក្សសាតាំង  ហើយផ្សះផ្សាយើងជាមួយនឹងព្រះជាម្ចាស់ឡើងវិញ។
ខ. អ្នកសង្គ្រោះគឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់។  ព្រះជាម្ចាស់មិនបានចាត់ទេវតាអោយមកសង្គ្រោះយើងទេ។  ព្រះជាម្ចាស់បានយាងមកផ្ទាល់តាមរយៈព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ  ដែលជាអ្នកបង្កើតពិភពលោក។  ព្រះរាជបុត្រារបស់ព្រះបានមកយកនិស្ស័យជាមនុស្ស កើតក្នុងសាសន៍អ៊ីស្រាអែល កាលពី ២០១០ឆ្នាំមុន។  ព្រះនាមរបស់ទ្រង់គឺ  យេស៊ូវ  ដែលមានន័យថា "ព្រះអង្គសង្គ្រោះ" ហើយទ្រង់មានភាពជាព្រះមួយរយភាគរយ  និងជាមនុស្សមួយរយភាគរយ ក្នុងបុគ្គលតែមួយ។
គ. ផ្ទុយពីអ័ដាម ព្រះយេស៊ូវមិនដែលធ្វើបាបសោះ ហើយទ្រង់ចុះចូលចំពោះព្រះវរបិតាគ្រប់ពេលវេលា។  ទ្រង់ពឹងលើព្រះគុណរបស់ព្រះ និងសេចក្តីពិតជានិច្ច។ (ចូរបង្ហាញថា  រូបភាពទី៤ និង រូបភាពទី ១ វាស្រដៀងគ្នា)។  ដោយសារទ្រង់ជាអ្នកបង្កើត  ទ្រង់មានអំណាចព្រះចេស្តាលើធម្មជាតិ  ជំងឺ សេចក្តីស្លាប់ និងសាតាំង។  គ្រប់ទាំងសេចក្តីបង្រៀនរបស់ទ្រង់ គឺជាសេចក្តីពិត ហើយល្អ។ (ចូរសូត្រ លូកា ១៩:១០)

រូបភាពទី ៥ :  អ្នកសង្គ្រោះសោយទិវង្សគុតជំនួយពួកបះបោរ
ក.  មនុស្សខ្លះនៅអ៊ីស្រាអែលបានច្រណែននឹងព្រះយេស៊ូវ ហើយសំលាប់ទ្រង់។   ព្រះគ្រីស្ទមានគ្រប់អំណាចចេស្តា  ហើយអាចបំផ្លាញសត្រូវរបស់ទ្រង់បានយ៉ាងងាយបំផុត  ក៏ប៉ុន្តែទ្រង់បានអនុញ្ញាតអោយពួកគេសំលាប់ទ្រង់នៅលើឈើឆ្កាង។
ខ. ព្រះយេស៊ូវបានដាច់ចេញពីព្រះជាម្ចាស់ជំនួសយើង។  ការនេះបានកើតឡើងតាមគម្រោងការរបស់ព្រះជាម្ចាស់។   ដោយសារសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង  ព្រះយេស៊ូវសុខចិត្តទទួលយកការដាក់ទោសចំពោះបាបរបស់យើង ដែលយើងសមនឹងទទួល។ ក្នុងអង្គទ្រង់ ទ្រង់បានទទួលសេចក្តីងងឹត នឹងបែកចេញពីព្រះជាម្ចាស់  ដែលយើងទាំងអស់គ្នាសមនឹងទទួល។  ព្រះយេស៊ូវដ៏សុចរិតបានស្លាប់ជំនួសពួកទុច្ចរិតដែលជាអ្នកបះបោរ  ដើម្បីផ្សះផ្សាយើងនឹងព្រះជាម្ចាស់។ (ចូរបង្ហាញភាពស្រដៀងគ្នារវាងរូបភាពទី ៥ និង រូបភាពទី ៣)
គ. សិស្សរបស់ព្រះយេស៊ូវបានបញ្ចុះសពទ្រង់ ហើយទ្រង់បាននៅក្នុងផ្នូររយៈពេលបីថ្ងៃ។   (ចូរសូត្រ ១ពេត្រុស ៣:១៨)  បើសិនរឿងនេះបានបញ្ចប់តែត្រឹមនេះ   នោះយើងគ្មានសង្ឃឹមសោះ  ព្រោះអ្នកសង្គ្រោះដែលស្លាប់រហូតមិនអាចជួយយើងបានឡើយ។

រូបភាពទី ៦:  ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ពីសុគតឡើងវិញ
ក. បីថ្ងៃបន្ទាប់មក  ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូវអោយរស់ពីសុគតឡើងវិញ. នេះមានន័យថា ព្រះជាម្ចាស់បានទទួល យញ្ញបូជាដែលព្រះយេស៊ូវគ្រីស្ទបានលះបង់ជីវិតជំនួសយើង។ វាមានន័យថា  ឥឡូវនេះ  ពួកយើងដែលជាអ្នកបះបោរ អាចផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ឡើងវិញបាន។  ហើយវាក៏មានន័យថា ព្រះយេស៊ូវគ្រីស្ទបានយកជ័យជំនះលើសេចក្តីស្លាប់   អំពើបាប និងសាតាំង។
ខ. សែសិបថ្ងៃក្រោយមក  ព្រះយេស៊ូវគ្រីស្ទបានយាងឡើងទៅស្ថានសួគ៌វិញ។    នៅស្ថានសួគ៌ព្រះយេស៊ូវគង់លើរាជបល្ល័ង្ក គឺទ្រង់ជាមហាក្សត្រនៃចក្រវាឡទាំងមូល។
គ. ថ្ងៃណាមួយព្រះយេស៊ូវនឹងយាងមកវិញដើម្បីនឹងជំនុំជំរះពិភពលោក។  យើងទាំងអស់គ្នានឹងត្រូវរៀបរាប់អំពីជីវិតរបស់យើងនៅចំពោះមុខព្រះយេស៊ូវនៅថ្ងៃជំនុំជំរះ។ (ចូរសូត្រ ១ពេត្រុស ១:៣)

រូបភាពីទី ៧ :   មានជំរើសតែពីរគត់
ក. ផ្លូវនៃអំពើបាប និងការបែកចេញពីព្រះជាម្ចាស់។    នេះមានន័យថា អ្នកមិនចង់បែរចេញពីបាប និងការបះបោររបស់អ្នកទេ។  អ្នកនៅតែចង់ធ្វើជាស្តេចលើជីវិតរបស់អ្នកផ្ទាល់។ តែផ្លូវនេះជាផ្លូវនៃសេចក្តីងងឹត  ផ្លូវនៃការបែកចេញពីព្រះជាម្ចាស់  ផ្លូវដែលនាំទៅស្ថាននរកអស់កល្បជានិច្ច។ តែជីវិតរបស់អ្នកមិនបាច់បញ្ចប់ដោយបែបនេះទេ។  អ្នកអាចជ្រើសរើសផ្លូវផ្សេងទៀតបាន :
ខ.  ផ្លូវនៃការប្រែចិត្ត ហើយជឿលើព្រះយេស៊ូវគ្រីស្ទ។    អស់អ្នកបះបោរណាដែលកែប្រែចិត្តពីការបះបោររបស់ខ្លួន  ហើយបន្ទាបខ្លួនចំពោះព្រះយេស៊ូវដែលជាមហាក្សត្រ   ហើយជឿថា ព្រះយេស៊ូវបានសុគតសំរាប់បាបរបស់អ្នក និង មានព្រះជន្មរស់ឡើងវិញ  នោះព្រះជាម្ចាស់អត់ទោសអោយគ្រប់ទាំងអំពើបាបរបស់អ្នក  ហើយទ្រង់ផ្សះផ្សាអ្នកនឹងព្រះជាម្ចាស់ឡើងវិញ។  អ្នកក្លាយជាកូនរបស់ព្រះជាម្ចាស់  ហើយទទួលអំណោយនៃជីវិតអស់កល្បជានិច្ច។ ព្រះវិញ្ញាណបរិសុទ្ធយាងមកគង់ក្នុងអ្នក  ដើម្បីអ្នកអាចរៀនអំពីសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់  និងសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ  នៅក្នុងព្រះរាជ្យរបស់ព្រះយេស៊ូវគ្រីស្ទ។
គ.  ខ្ញុំសុំអង្វរអោយអ្នកជ្រើសរើស ផ្លូវនៃការប្រែចិត្ត ហើយជឿលើព្រះយេស៊ូវគ្រីស្ទ។   សុំនិយាយទៅកាន់ព្រះជាម្ចាស់។  សុំសារភាពចំពោះទ្រង់ថា អ្នកបានបះបោរប្រឆាំងនឹងទ្រង់  ហើយថា បាបរបស់អ្នកទាំងអស់សមនឹងទទួលការដាក់ទោសពីទ្រង់។  សុំបែរចេញពីការគ្រប់គ្រងជីវិតដោយខ្លួនឯង  ហើយសុំអោយព្រះយេស៊ូវធ្វើជាអ្នកគ្រប់គ្រងរបស់អ្នកវិញ។  សុំជឿថាព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាងសំរាប់បាបរបស់អ្នក ហើយទ្រង់បានរស់ឡើងវិញ។ ចូរសូមអោយព្រះសង្គ្រោះអ្នក នោះទ្រង់នឹងសង្គ្រោះអ្នកជាពិត។  (ចូរសូត្រ យ៉ូហាន ៣:៣៦)

© J.D. Crowley jamesdcrowley@gmail.com    (This presentation relies heavily on *"Two Ways to Live,"* Matthiasmedia.com or twowaystolive.com, but has been contextualized for the Cambodian context with permission.)